រដ្ឋសភា
ចូល
លេខ ៨៤២
ថ្ងៃទី.......ឆ្នាំ.......ម៉ោង.......
បញ្ជូនទៅ.......

# ព្រះរាជក្រម

នស/រកម/០៣១៨/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៩៣/០០១/២០១៨ កបធ.ច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា ២៦ មាត្រា ២៧ថ្មី មាត្រា ២៨ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា២៦.១.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ឬរបស់បេក្ខជន ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនរបស់ខ្លួន។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលរដ្ឋសភា ត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួនឬសាមីគណបក្សនយោបាយ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះជាបន្ទាន់ ។

សវនាការ ឬផ្នែកមួយនៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលវិនិច្ឆ័យលើបណ្តឹងតវ៉ាត្រូវធ្វើជាចំហ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបិទផ្សាយថ្ងៃ ខែ ឆ្នាំ ទីកន្លែង និងពេលវេលានៃការបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ានេះ ។

**មាត្រា២៦.២.-ថ្មី**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាងចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបដិសេធបណ្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតរបស់ខ្លួន។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបាន សេចក្តីចម្លង សេចក្តីសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

